# ការធ្វើប្រជាមតិលើសំឡេងជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait

ពលរដ្ឋអូស្ត្រាលីនឹងត្រូវបានស្នើសុំឱ្យបោះឆ្នោតប្រជាមតិមួយនាពេលឆាប់ៗនេះ។ ប្រជាមតិនឹងសួរថាតើគួរតែមាន សំឡេងជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait ទៅកាន់រដ្ឋសភានៅក្នុងរដ្ឋធម្មនុញ្ញដែរទេ។ រដ្ឋសភា គឺជាស្ថាប័នដែលបង្កើតច្បាប់សម្រាប់ប្រទេសអូស្ត្រាលី។

## តើសំឡេងទៅកាន់រដ្ឋសភាគឺជាអ្វី?

សំឡេងគឺជាមធ្យោបាយមួយសម្រាប់ជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait ដើម្បីផ្តល់ដំបូន្មានដល់ រដ្ឋាភិបាលអំពីច្បាប់នានាដែលប៉ះពាល់ដល់ពួកគេ។ ការសរសេរសំឡេងទៅក្នុងរដ្ឋធម្មនុញ្ញនឹងមានន័យថា សំឡេងនឹងមានតួនាទីជាអចិន្ត្រៃយ៍ក្នុងការផ្តល់ដំបូន្មានដល់រដ្ឋាភិបាល លើបញ្ហានានាដែលប៉ះពាល់ដល់ជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait។ សំឡេងទៅកាន់រដ្ឋសភា នឹងក្លាយជាឱកាសមួយសម្រាប់ជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait ដើម្បីឱ្យមានការទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ និងដើម្បីទទួលស្គាល់ និងការអបអរសាទរវប្បធម៌របស់ពួកគេ។

## ហេតុអ្វីបានជាជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait ស្នើសុំឱ្យមានសំឡេងទៅកាន់រដ្ឋសភា?

ជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait បានស្នើសុំឱ្យមានការទទួលស្គាល់ដោយរដ្ឋាភិបាលជិត 100ឆ្នាំមកហើយ។ ជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait ស្គាល់ពីសហគមន៍ និងវប្បធម៌របស់ ពួកគេយ៉ាងល្អបំផុត។ ពួកគេដឹងពីដំណោះស្រាយដ៏ល្អបំផុត ដើម្បីដោះស្រាយបញ្ហានានាដែលកំពុងប្រឈមមុខ នឹងសហគមន៍របស់ពួកគេ ដែលអាចបង្កើតនូវបទពិសោធន៍ប្រកបដោយយុត្តិធម៌ និងសមធម៌ជាងមុនសម្រាប់ ជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait។

## តើសំឡេងទៅកាន់រដ្ឋសភានឹងធ្វើអ្វីខ្លះ?

សំឡេងនឹងស្តាប់ដំបូន្មានជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait អំពីបញ្ហានានាដែលប៉ះពាល់ ដល់ជីវិតរបស់ពួកគេ ដើម្បីឱ្យរដ្ឋាភិបាលអាចធ្វើការសម្រេចចិត្តបានកាន់តែល្អប្រសើរ ដែលផលប៉ះពាល់ដល់ ជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait ។

## តើនរណានឹងជាអ្នកតំណាងឱ្យសំឡេងទៅកាន់រដ្ឋសភា?

សំឡេងនឹងជាក្រុមមួយនៃជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait ដែលមកពីគ្រប់រដ្ឋ និងដែនដី រួមទាំងតំបន់ដាច់ស្រយាលផងដែរ។ អ្នកតំណាងនឹងត្រូវបានជ្រើសរើសដោយជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait ក្នុងតំបន់មូលដ្ឋានរបស់ពួកគេ។

## តើជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait ធ្លាប់បានពិគ្រោះយោបល់លើសំឡេងទៅកាន់រដ្ឋសភាដែរឬទេ?

ជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait រាប់ពាន់នាក់ ធ្លាប់បានផ្តល់ដំបូន្មានអំពីហេតុផលដែលត្រូវការ សំឡេង និងរបៀបដែលវាគួរតែដំណើរការរយៈពេលជាច្រើនឆ្នាំមកហើយ។ ជាង 80% នៃជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait គាំទ្រសំឡេងទៅកាន់រដ្ឋសភា។



អនុញ្ញាតដោយ Tabatha Feher, Life Without Barriers, L6, 107 Pitt St, Sydney, NSW.

## តើអ្នកជំនាញច្បាប់និយាយអ្វីខ្លះ?

មេធាវីរដ្ឋធម្មនុញ្ញ រួមទាំងអ្នកតំណាងឱ្យរដ្ឋាភិបាលសហព័ន្ធបាននិយាយថា សំឡេងគឺត្រឹមត្រូវស្របច្បាប់ ហើយវានឹងធ្វើឱ្យប្រព័ន្ធរដ្ឋាភិបាលរបស់យើងកាន់តែប្រសើរឡើង។

## តើសំឡេងអាចបង្កើតច្បាប់ដែរឬទេ?

ទេ សំឡេងនឹងមិនមានអំណាចបង្កើតច្បាប់ទេ។ សំឡេងនឹងផ្តល់ ដំបូន្មានតែលើបញ្ហានានាដែលប៉ះពាល់ដល់ ជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait ប៉ុណ្ណោះ។

## តើសំណួរអ្វីដែលប្រជាមតិលើសំឡេងជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait នឹងស្នើឡើង?

“ច្បាប់ដែលបានស្នើឡើង៖ ដើម្បីកែប្រែរដ្ឋធម្មនុញ្ញក្នុងការទទួលស្គាល់ជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait នៃប្រទេសអូស្ត្រាលី ដោយការបង្កើតសំឡេងជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait ។ តើអ្នកយល់ព្រមលើការកែប្រែដែលបានស្នើឡើងនេះទេ?”

## តើខ្ញុំបោះឆ្នោតប្រជាមតិដោយរបៀបណា?

ការធ្វើប្រជាមតិគឺដូចជាការបោះឆ្នោតនានាដែរ។ អ្នកនឹងត្រូវបានផ្តល់សន្លឹកឆ្នោតមួយសន្លឹក ជាមួយនឹងសំណួរ ខាងលើ ហើយអ្នកនឹងត្រូវសរសេរ ‘YES’ ឬ ‘NO’ ជាភាសាអង់គ្លេស ដើម្បីឱ្យការបោះឆ្នោតរបស់អ្នកត្រូវបានរាប់ ជាផ្លូវការ។ ប្រសិនបើអ្នកសរសេរ ‘YES’ មានន័យថា អ្នកយល់ព្រមថាជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait គួរតែមានសំឡេងលើបញ្ហានានាដែលប៉ះពាល់ ដល់ពួកគេផ្ទាល់។

## តើមានអ្វីកើតឡើងប្រសិនបើពលរដ្ឋភាគច្រើនបោះឆ្នោត YES?

ប្រសិនបើពលរដ្ឋភាគច្រើនបោះឆ្នោត Yes សម្រាប់សំឡេង រដ្ឋាភិបាលនឹងពិគ្រោះយោបល់ជាមួយជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait ដើម្បីបញ្ចប់ការកំណត់ និងអនុម័តច្បាប់ពាក់ព័ន្ធនានាដើម្បីរៀបចំ បង្កើតសំឡេង។

## តើនឹងមានអ្វីកើតឡើង ប្រសិនបើពលរដ្ឋភាគច្រើនបោះឆ្នោត NO?

ប្រសិនបើប្រជាពលរដ្ឋភាគច្រើនបោះឆ្នោត ‘No’ នោះគ្មានអ្វីកែប្រែទេ។ បញ្ហានានាដែលកំពុងប្រឈមមុខចំពោះ ជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait នឹងនៅតែបន្ត។ ការបោះឆ្នោត ‘No’ មានន័យថា អ្នកបោះឆ្នោត No ឱ្យសំឡេង វាគ្មានជម្រើសផ្សេងទៀតដើម្បីគាំទ្រដល់ជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait នៅក្នុងការធ្វើប្រជាមតិនេះទេ។

## តើខ្ញុំអាចទទួលបានព័ត៌មានបន្ថែមនៅឯណា?

**ព័ត៌មាន បន្ថែម**

www.lwb.org.au



អនុញ្ញាតដោយ Tabatha Feher, Life Without Barriers, L6, 107 Pitt St, Sydney, NSW.